# Summary of Boating Regulations and Water Safety Tips

## Boat Licenses

Most boats are required to be licensed with the Minnesota Department of Natural Resources (DNR). This includes motorboats, rowboats, canoes and kayaks. Boats with no motors that are nine feet in length or shorter do NOT need to be licensed. Boats are required to display the registration number and validation decal on both sides of the forward half of the craft. Boats used: 1) for duck hunting during the duck season and 2) for harvesting rice during the wild rice harvest season are exempt from licensing. For information on how to obtain a boat license, contact the DNR Registration & Titling Section (651) 296-2316 or toll free (800) 285-2000.







## Life Preservers

On all boats, there must be a readily accessible U.S. Coast Guard approved wearable life jacket for each person on board. Readily accessible means that the life jacket can be easily retrieved within a reasonable amount of time in an emergency. Life jackets must be in good condition and of the proper size and type for the person it is intended.

In addition, on boats 16 feet and longer (except canoes and kayaks) there must also be at least one U.S. Coast Guard approved Type IV throwable device immediately available. In most cases this will be a buoyant seat cushion. If someone falls out of the boat or is in trouble in the water, throw the cushion to the person and tell them to hang on to it until they can be rescued.

Children under ten years old must wear a life jacket when on board any boat while it is underway. Underway means not attached to a permanent mooring or tied to a dock.

It is a smart idea for everyone to always wear a life jacket when in a boat. There just isn't time to put one on before an accident happens.







## Boat Lights

Boats are required to have lights between sunset and sunrise. Non-motorized boats must carry at least a white light, such as a flashlight, to display in time to avoid a collision with other watercraft. Motorboats, when moving, must have a red and green bow light and a white stern light that is visible from 360 degrees around the boat. If your motorboat is anchored you need to display only the 360-degree light.



## Boat Operator Ages

There are age restrictions for children under 18 years old operating motorboats. Please check with the DNR for more information before allowing a child to drive a motorboat.

## Tubing

Tubing behind a boat should be done at a slow speed and only good swimmers wearing life jackets should be passengers on the tube. Turns should be made gradually and away from shore, other boats, swim rafts and docks to reduce the chance of a collision. There must be either an observer, or a wide-angle rearview mirror so the boat operator can watch the tubers.




## Dams

There are powerful currents near the base of both large and small dams that can trap a person or boat. It is best to stay well away from dams. On the Mississippi River, (except in the lock approach areas) you may not operate your boat closer than 600 feet above nor 150 feet below any dam from Minneapolis to the Iowa border.

## Swimming Safety

It is always best to swim at a beach or pool where lifeguards are on duty. Children should receive swimming lessons and also be watched very closely while they are in the water – even if there are lifeguards. Avoid swimming in ponds, rivers and water-filled gravel pits.

## Children and Water

Always watch children around water even when they are not swimming – water is fascinating to them and they do not realize it can also be dangerous.

## Getting help

In any emergency situation on the water, call **911** immediately on a cell or regular phone and describe the problem and where you are. Stay on the line to help emergency responders find you.

**For more information, call:**

(Metro Area) (651) 259-5400 (MN Toll Free) 1-888-646-6367
Telecommunication Device for the Deaf
(Metro Area) (651) 296-5484 (MN Toll Free) 1-800-657-3929
e-mail: boatandwater@dnr.state.mn.us

*www.mndnr.gov/boating*

This document is available in alternative formats to individuals with disabilities by calling the phone numbers above.

Equal opportunity to participate in and benefit from programs of the Minnesota Department of Natural Resources is available to all individuals regardless of race, color, creed, religion, national origin, sex, marital status, public assistance status, age, sexual orientation, disability or activity on behalf of a local human rights commission. Discrimination inquiries should be sent to Minnesota Department of Natural Resources, 500 Lafayette Road, St. Paul, MN 55155 - 4049.

Printed on recycled paper containing a minimum of 30% post-consumer waste.
© Copyright 2008, State of Minnesota, Department of Natural Resources 2/08-5M



# សេចក្តីសង្ខេប អំពីច្បាប់ប្រើជិនិះផ្លូវទឹក និង សុវត្ថិភាពក្នុងទឹក

## ប័ណ្ណអនុញ្ញាតិបើកបរជិនិះផ្លូវទឹក

ជិនិះផ្លូវទឹកភាគច្រើន ត្រូវគេតម្រូវឲ្យមាន ប័ណ្ណអនុញ្ញាតិឲ្យ តាមរយៈក្រសួងធនធាន ធម្មជាតិនៃរដ្ឋ មីនេសូតា (DNR)។ ជិនិះផ្លូវទឹក គឺមានរាប់ចូលទាំង កាណូត ទូកចែវ ទូកកាន្ទូ និង ទូកខាយ៉ាក់។ ជិនិះផ្លូវទឹកគ្មានម៉ាស៊ីន ដែលមានប្រវែងប្រាំបួនហ្វីត ឬខ្លីជាងនោះ មិនបាច់មានប័ណ្ណអនុញ្ញាតិបើកទេ។ ជិនិះផ្លូវទឹកត្រូវគេតម្រូវឲ្យដាក់លេខចុះឈ្មោះ និងប្លាកសុពលភាព នៅទាំង សងខាងនៃភាគមួយ កំណាត់ខាងមុខរបស់យានទាំងនេះ។ ជិនិះផ្លូវទឹកដែលប្រើសំរាប់: ១) សំរាប់បាញ់ទានៅរដូវទា និង ២) សំរាប់ច្រូតស្រូវនៅរដូវចម្រូតស្រូវស្រង៉ៃ មិនបាច់មានប័ណ្ណអនុញ្ញាតិទេ។ ដើម្បីនឹងទទួលពត៌មាន អំពីរបៀបសុំសំបុត្រអនុញ្ញាតិ ប្រើជិនិះផ្លូវទឹក សូមទាក់ទងជាមួយ DNR សាខា ខាងចុះឈ្មោះ និងលិខិតបញ្ជាក់នៅលេខ (651) 296-2316 ឬលេខឥតយកកំរៃ (800) 285-2000។







## ប្រដាប់ប្រដាសំរាប់ជួយរក្សាជីវិត

នៅក្នុងជិនិះផ្លូវទឹកទាំងអស់ ត្រូវតែមានអាវការពារជីវិត ដែលយកមកប្រើដោយស្រួល ហើយដែលអង្គ ការអ្នកការពារយាមឆ្នេរនៃសហរដ្ឋទទួលស្គាល់ សំរាប់មនុស្សរាល់គ្នាដែលនៅក្នុងជិនិះផ្លូវទឹក។ យក មកប្រើដោយស្រួលបានន័យថា គេអាចនឹងយកអាវការពារជីវិត មកប្រើបានដោយប្រើរយៈ ពេលសមរម្យនៅក្នុងករណីអាសន្ន។ អាវការពារជីវិតត្រូវតែនៅមានលក្ខណៈល្អ និងមានទំហំ និងប្រភេទ ត្រូវ សំរាប់អ្នកដែលត្រូវប្រើ។

បន្ថែមពីនោះ នៅលើជិនិះផ្លូវទឹកដែលមានប្រវែង 16 ឬ លើសពី 16 ហ្វីត (លើកលែងតែទូកកាន្ទូ និង ទូកខាយ៉ាក់) ត្រូវតែមានប្រដាប់ដែលបោះបាន ជំពូក IV ដែលអ្នកការពារយាមឆ្នេរនៃសហរដ្ឋ ទទួល ស្គាល់ យ៉ាងតិចមួយដែរ។ ក្នុងករណីភាគច្រើន ប្រដាប់នេះគឺជាពូកទ្រាប់អង្គុយដែលអណ្តែតលើទឹក។ បើអ្នកណាធ្លាក់ចេញពីជិនិះផ្លូវទឹកចូលក្នុងទឹក ឬមានបញ្ហានៅក្នុងទឹក សូមបោះពូកទៅអ្នកនោះ ហើយ ប្រាប់គេឲ្យតោងពូកនោះ រហូតដល់ពេលមានគេទៅជួយស្រោចស្រង់។

កូនក្មេងក្រោម 10 ឆ្នាំ ត្រូវតែពាក់អាវការពារជីវិត កាលណានៅក្នុងជិនិះផ្លូវទឹកនៅពេលដែលជិនិះផ្លូវ ទឹក នោះកំពុងធ្វើដំណើរ។ កំពុងធ្វើដំណើរបានសេចក្តីថា មិនចតជាអចិន្ត្រៃយ៍ ឬចងជាប់ទៅនឹងផែ។

គឺជាគំនិតល្អសំរាប់មនុស្សគ្រប់ទាំងអស់ ត្រូវពាក់អាវការពារជីវិតជានិច្ច នៅពេលដែលនៅជិះជិនិះផ្លូវ ទឹក។ គឺគ្មានពេលពាក់ទេ នៅមុនពេលគ្រោះ ថ្នាក់កើតឡើងនោះ។

16 ហ្វីត ឬ វែងជាង 16 ហ្វីត
លើកលែងតែទូកកាន្ទូ និងទូកខាយ៉ាក់




ខ្លីជាង 16 ហ្វីត ឬ ទូកកាន្ទូ
និងទូកខាយ៉ាក់ ទំហំប៉ុន្មានក៏ដោយ



## ភ្លើងបំភ្លឺជិនិះផ្លូវទឹក

ជិនិះផ្លូវទឹកត្រូវមានភ្លើងបំភ្លឺ ពីពេលថ្ងៃលិច និងដល់ថ្ងៃរះ។ ជិនិះផ្លូវទឹកដែលគ្មានម៉ាស៊ីនត្រូវយ៉ាង ហោចណាស់ មានចង្កៀងពន្លឺសមួយ ដូចជាកែវឆ្លុះដើម្បីឆ្លុះបង្ហាញខ្លួនពេលខ្លះ ដើម្បីកុំឲ្យបុកគ្នាជា មួយជិនិះផ្លូវទឹកឯទៀត។ ជិនិះផ្លូវទឹកមានម៉ាស៊ីន នៅពេលដែលបើកបរ ត្រូវតែមានភ្លើងក្រហមនិង បៃតងនៅខាងមុខ និងភ្លើងសនៅកន្សៃ ដែលគេអាចមើលជុំវិញជិនិះផ្លូវទឹកទាំង 360 អង្សា។ បើ ជិនិះផ្លូវទឹកមានម៉ាស៊ីនរបស់លោកអ្នកនៅដាក់ជាប់នឹងយុថ្កា លោកអ្នកត្រូវតែបង្ហាញភ្លើង ដែលគេ អាចមើលជុំវិញជិនិះផ្លូវទឹកទាំង 360អង្សាប៉ុណ្ណោះ។



## អាយុនៃអ្នកបើកបរជិនិះផ្លូវទឹក

មានការកំរិតហាមឃាត់មិនឲ្យក្មេងដែលមានអាយុក្រោម18 ឆ្នាំបើកបរជិនិះផ្លូវទឹកមានម៉ាស៊ីន។ សូម ទាក់ទងជាមួយ DNR ដើម្បីយកពត៌មានបន្ថែម មុននឹងអនុញ្ញាតឲ្យកូនក្មេងបើកបរជិនិះផ្លូវទឹកមាន ម៉ាស៊ីន។

## ការប្រើពោង

ការប្រើពោងនៅខាងក្រោយជិនិះផ្លូវទឹក គួរតែធ្វើទៅដោយបើកល្បឿនយឺត ហើយមានតែអ្នកចេះហែលទឹកបានល្អប៉ុណ្ណោះ ដែលមានពាក់អាវការពារជីវិតត្រូវជិះពោង។ ពេលបត់ត្រូវបត់បន្តិចម្តង និងនៅឆ្ងាយពីច្រាំង ឆ្ងាយពីជិនិះផ្លូវទឹកឯទៀត ក្បូនហែល និងផែដើម្បីចៀសវាងកុំឲ្យមានការបុកគ្នា។ ឬមួយត្រូវមានអ្នកមើល ឬកញ្ចក់ដែលមើលបានរង្វង់មុមធំ សំរាប់ឲ្យអ្នកបើកបរជិនិះផ្លូវទឹក មើលអ្នកជិះពោងឃើញ។




## ទំនប់ទឹក

មានចរន្តខ្លាំងនៅជិតផ្នែកខាងក្រោមនៃទំនប់ទំហំធំឬតូច ដែលអាចធ្វើឲ្យមនុស្សឬជិនិះផ្លូវទឹកចេញមិន រួច។ ជាការល្អប្រសើរ ត្រូវចៀសឱ្យឆ្ងាយពីទំនប់។ នៅលើទន្លេមីស៊ីសស៊ីពី (លើកលែងតែម្តុំជិត កន្លែងបិតបើកស្ពាន) លោកអ្នកមិនត្រូវបើកបរជិនិះផ្លូវទឹករបស់លោកអ្នក ជិតជាង 600 ហ្វីត នៅផ្នែកខាងលើនៃទំនប់ឬ 150 ហ្វីតនៅផ្នែកខាងក្រោមនៃទំនប់ ចាប់ពីមីនីអាប៉ូលីស ទៅដល់ជាយ ដែនអាយយ៉ូវ៉ា។

## សុវត្ថិភាពក្នុងការហែលទឹក

ជាការល្អប្រសើរ បើហែលទឹកនៅឆ្នេរខ្សាច់ ឬនៅអាងហែលទឹកដែលមានអ្នកយាមការពារជីវិត នៅធ្វើការ។ កូនក្មេងគួរតែរៀនរបៀបហែលទឹក និងត្រូវមានមនុស្សមើលតាមដានឲ្យជាប់ដែរ នៅពេលដែល គេនៅក្នុងទឹក - ទោះបីមានអ្នកយាមការពារជីវិតក៏ដោយ។ ចូរចៀសវាងកុំហែលទឹក នៅក្នុងស្រះ ទន្លេ និងអន្លង់ទឹកដែលគេជីកយកក្រួស។

## កូនក្មេងនិងទឹក

ត្រូវមើលក្មេងជានិច្ចនៅពេលដែលពួកគេនៅជិតទឹក ទោះបីពួកគេមិនហែលទឹកក៏ដោយ - ទឹកតែងតែ ទាក់ទាញចិត្តក្មេង ហើយពួកគេមិនបានចាប់អារម្មណ៍ថាទឹកអាចនឹងផ្តល់គ្រោះថ្នាក់ដែរ។

## រកជំនួយ

នៅពេលមានអាសន្ននៅក្នុងទឹក ចូរទូរស័ព្ទហៅទៅលេខ **911** ភ្លាម ដោយប្រើទូរស័ព្ទដៃ ឬទូរស័ព្ទ ធម្មតា និងពណ៌នាបញ្ហា និងទីកន្លែងប្រាប់ដល់គេ។ នៅចាំស្តាប់រហូត ដើម្បីជួយអ្នកជំនួយបន្ទាន់ឲ្យរក លោកអ្នកឃើញ។

---

**ដើម្បីទទួលពត៌មានបន្ថែម សូមហៅទូរស័ព្ទទៅលេខ:**

(ក្នុងបរិវេណក្រុង) (651) 259-5400 (មីនីសូតាលេខឥតយកកំរៃ) 1-888-646-6367
ទូរស័ព្ទសំរាប់មនុស្សថ្លង់
(ក្នុងបរិវេនក្រុង) (651) 296-5484 (មីនីសូតាលេខឥតយកកំរៃ) 1-800-657-3929
អ៊ីមាល: boatandwater@dnr.state.mn.us
*www.mndnr.gov/boating*

ឯកសារនេះមានរៀបចំជារបៀបផ្សេង សំរាប់មនុស្សពិការ ដែលអាចទទួលបានដោយហៅទៅលេខ ទូរស័ព្ទដែលមាននៅខាងលើនេះ។

កាលានុវត្តភាពស្មើគ្នា ក្នុងការចូលរួមនិងទទួលផលប្រយោជន៍ ពីក្រសួងធនធានធម្មជាតិនៃរដ្ឋ មីនីសូតា មានសំរាប់អ្នកទាំងអស់ ទោះបីគេមាន ជាតិសាសន៍ ពណ៌ សម្បុរ ទំនៀមទម្លាប់ សាសនា ជាតិសាសន៍ដើម ភេទ លីវឬមានប្តីប្រពន្ធ ទទួលប្រាក់រដ្ឋឬអត់ អាយុ ចំណូលខាងរួមភេទ ពិការភាព ឬ សកម្មភាពដំណាងសិទ្ធិមនុស្សនៅក្នុងស្រុកភូមិអ្វីក៏ដោយ។ ការស៊ើបសួរ ពីការប្រកាន់ ត្រូវផ្ញើទៅ ក្រសួងធនធានធម្មជាតិនៃរដ្ឋមីនីសូតា 500 Lafayette Road, St. Paul, MN 55155 – 4049។

បោះពុម្ពលើក្រដាស់ដែលប្រើឡើងវិញ ដែលមានចំនួនជាតិដែលប្រើឡើងវិញយ៉ាងតិច 30%។
© រក្សាសិទ្ធិ 2008, រដ្ឋមីនេសូតា ក្រសួងធនធានធម្មជាតិ 2/08-5M